**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៩៦២ អយក. ទប

ចុះលេខ ខ.ទក ថ្ងៃទី 29 ខែ 09
ឆ្នាំ 2014 ម៉ោង 8h 15 mn
ចុះបញ្ជីលេខ 599

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុៈ របាយការណ៍ស្តីពី "សមិទ្ធផលនៃការអនុវត្តវិធានការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា រយៈពេល ១ ឆ្នាំ" ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ៖ បន្ទាប់ពីទទួលបានអនុសាសន៍ណែនាំឱ្យគ្រប់ក្រសួង ស្ថាប័ន ធ្វើរបាយការណ៍បូកសរុបសមិទ្ធផលការងារកំណែទម្រង់ រយៈពេល ១ ឆ្នាំ នៃរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការប្រជុំវាយតម្លៃ និងធ្វើរបាយការណ៍បូកសរុបសមិទ្ធផលការងារកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដែលបានអនុវត្តវិធានការជាក់ស្តែងរយៈពេល ១ ឆ្នាំកន្លងមក ។

ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេចតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ នៃរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការ អាទិភាព ៨ ចំណុច ក្នុងគោលដៅធ្វើកំណែទម្រង់ស៊ីជម្រៅ វិស័យអប់រំ យុវជន និងកីឡា។ រយៈពេល ១ ឆ្នាំ នៃការអនុវត្តវិធានការកំណែទម្រង់នេះ ក្រសួងអប់រំ យុវជន និងកីឡា សម្រេចបានសមិទ្ធផល ដូចខាងក្រោម៖

**១. វឌ្ឍនភាពនៃការអនុវត្តវិធានការកំណែទម្រង់ទាំង ៨**

វិធានការទី ១ ៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ

-ក្រសួងបានរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១៤-២០១៨ ។ គោលនយោបាយនិងផែនការសកម្មភាពស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចត្រូវ បានប្រកាសដាក់ឱ្យប្រើប្រាស់ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤

-ក្រសួងមានគម្រោងរៀបចំសាកល្បង សាលារៀនជំនាន់ថ្មីសម្រាប់អនាគត ដែលមានគោលដៅបង្កើតឱ្យមានមូលនិធិសមធម៌ ដើម្បីលើកកម្ពស់ជីវភាពគ្រូបង្រៀន និងគុណភាពអប់រំ

-ក្រសួងកំពុងសិក្សាបង្កើតសាលារៀនគំរូនៅមធ្យមសិក្សា ដោយផ្តោតលើគុណភាពគ្រូបង្រៀន ការ អនុវត្តបទបញ្ជាផ្ទៃក្នុង បរិស្ថានសាលា សម្ភារបរិក្ខារ រួមបញ្ចូលទាំងសម្ភារពិសោធ និងភាសាបរទេស

-ក្រសួងបានលើកគម្រោងសាងសង់សាលាមធ្យមសិក្សាបន្ថែម សំដៅបង្កើនលទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សាកាន់តែច្រើន



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៤៣ /២១៧ ២៥៣ /៤២៦ ៨៤១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

-ក្រសួងបាន និងកំពុងសិក្សាបង្កើនប្រាក់ឧបត្ថម្ភអាហារូបករណ៍សម្រាប់សិស្សក្រីក្រ នៅមធ្យមសិក្សាបឋមភូមិ និងសិស្សក្រីក្រ និងពូកែនៅមធ្យមសិក្សាទុតិយភូមិ

-ក្រសួងបានរៀបចំសេចក្តីណែនាំស្តីពី វិធានការអនាម័យសម្រាប់កម្មវិធីស្បៀងអាហារពេលព្រឹកនៅតាមគ្រឹះស្ថាន និងរៀបចំសេចក្តីព្រាងស្តង់ដាអប្បបរមាស្តីពីទឹកស្អាត និងអនាម័យសម្រាប់ សាលាបឋមសិក្សា

-ក្រសួងបានបង្កើតគណៈកម្មការចុះត្រួតពិនិត្យការដាក់តាំងលក់សៀវភៅសិក្សា ដែលមានស្លាក ហាមលក់ នៅលើទីផ្សារ

-ក្រសួងបានបញ្ចប់ការកសាងគោលនយោបាយស្តីពីគ្រូបង្រៀន និងកំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយនេះសំដៅកែលម្អគុណភាពគ្រូបង្រៀននៅកម្ពុជា

-ក្រសួងកំពុងរៀបចំក្របខណ្ឌធានាគុណភាពអប់រំ ក្រោមកិច្ចសហការជាមួយអធិការដ្ឋានអប់រំនៃប្រទេសស៊ុយអែត ដោយរួមបញ្ចូលទាំងការរៀបចំការងារអធិការកិច្ចខាងក្នុង និងខាងក្រៅក្រសួង ត្រៀមបណ្តុះបណ្តាលអធិការ សម្រាប់ធ្វើអធិការកិច្ចការគ្រប់គ្រងសាលារៀន និង គ្រូបង្រៀន តាមរយៈយន្តការ និងនីតិវិធីថ្មី ។ ក្រសួងបានបញ្ចប់ការធ្វើតេស្តថ្នាក់ជាតិ ថ្នាក់ទី ៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា

-ក្រសួងកំពុងពិនិត្យឡើងវិញ និងកែលម្អគោលនយោបាយកម្មវិធីសិក្សា និងសៀវភៅសិក្សាគ្រប់កម្រិត។ ក្រសួងបានរៀបចំម៉ូឌុលបំណិនជីវិតថ្នាក់ទី ៨ សៀវភៅភាសាអង់គ្លេស សម្រាប់សិស្ស ថ្នាក់ទី ៨ ស្តង់ដាបណ្ណាល័យមធ្យមសិក្សា ។

-ក្រសួងបានអនុមតិ និងដាក់ឲ្យប្រើប្រាស់ស្តង់ដារអំណាន និងល្បែងអក្ខរកម្មហិរញ្ញវត្ថុ ក្នុងគោលដៅពង្រឹងការអាន និងការបង្រៀនអក្ខរកម្មហិរញ្ញវត្ថុនៅកម្រិតបឋមសិក្សា

វិធានការទី ២ ៖ ការពង្រឹងការគ្រប់គ្រងបុគ្គលិក

-ក្រសួងបានអនុវត្តការបើកប្រាក់បៀវត្សរបស់បុគ្គលិកអប់រំ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិតាមប្រព័ន្ធធនាគារ ១០០% នៅត្រឹមខែមិថុនា ឆ្នាំ២០១៤ ។ ក្រសួងបានលើកទឹកចិត្ត និងធ្វើ និយ័តកម្មថ្នាក់ និងឋានន្តរស័ក្តិដល់បុគ្គលិកអប់រំ ដែលខកខានមិនបានឡើងថ្នាក់ ឬ ឋានន្តរស័ក្តិ តាមវេន និងអតីតភាពកន្លងមក

-ក្រសួងបានពិនិត្យឡើងវិញនីតិវិធី នៃការរៀបចំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានា សម្រាប់គ្រូចេញថ្មី ដើម្បីពន្លឿនការរៀបចំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភគ្រូចេញថ្មីឲ្យបានទាន់ពេលវេលា

-ក្រសួងបានអនុវត្តគោលការណ៍ស្តីពីការរក្សាទុកប្រាក់បំណាច់មុខងារ របស់អតីតបុគ្គលិកអប់រំដែលបានប្រឡងជាប់ជាគរុសិស្ស-និស្សិត នៃមជ្ឈមណ្ឌលគរុកោសល្យភូមិ និងវិទ្យាស្ថានជាតិ អប់រំ

-ក្រសួងបានពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបង្កើនប្រាក់បំណាច់មុខងារ របស់បុគ្គលិកអប់រំដោយបានរួមបញ្ចូលគ្នាប្រាក់កម្រៃគរុកោសល្យ ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យ សុខភាពឲ្យទៅជាប្រាក់បំណាច់មុខងារអប់រំ

-ក្រសួងបានកែសម្រួលគោលការណ៍ស្តីពីការតែងតាំងមន្ត្រីគ្រប់គ្រង ដោយអនុវត្តតាមប្រព័ន្ធវាយតម្លៃដាក់ពិន្ទុលើលទ្ធផលការងារ និងគុណវុឌ្ឍិរបស់មន្ត្រីម្នាក់ៗ សំដៅពង្រឹងប្រសិទ្ធភាព នៃការតែងតាំងមន្ត្រីគ្រប់គ្រង

-ក្រសួងបានផ្សព្វផ្សាយនិងអនុវត្តគោលការណ៍ស្តីពីការដំឡើងថ្នាក់ជាស្វ័យប្រវត្តិជូនបុគ្គលិកអប់រំ

-ក្រសួងបានបញ្ចប់ការកែសម្រួលឯកសារស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងអនុវត្តសាកល្បងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង មណ្ឌលគិរី និងខេត្តស្វាយរៀង ចាប់ពីឆ្នាំសិក្សា ២០១៤-២០១៥ សំដៅពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំ

-ក្រសួងបានបញ្ចប់ការកសាងឯកសារស្តីពីការពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ និងអនុវត្តសាកល្បង ចាប់ពីឆមាសទី២ ឆ្នាំ២០១៤។

វិធានការទី ៣ ៖ ការពង្រឹងការប្រឡងគ្រប់ប្រភេទ

-កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សានៅឆ្នាំនេះ បានបណ្តុះស្មារតី ភាពជឿទុកចិត្តរបស់បេក្ខជន និងអាណាព្យាបាលសិស្ស ក្រោមពាក្យស្លោក "អ្នកចេះជាប់"

-ក្រសួងបានធ្វើឱ្យមានការទុកចិត្តពីសំណាក់អ្នកពាក់ព័ន្ធមកលើដំណើរការប្រឡង ដោយលុបបំបាត់ និងទប់ស្កាត់រាល់ភាពមិនប្រក្រតីនានា ព្រមទាំងលើកតម្លៃរបស់បុគ្គលិកអប់រំ

-ក្រសួងប្រគល់សិទ្ធិអំណាច និងការទទួលខុសត្រូវទាំងស្រុងជូនសាលារៀននីមួយៗ ជាអ្នករៀបចំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ចាប់តាំងពីការរៀបចំប្រធានវិញ្ញាសា ដំណើរការ សំណេរ កំណែ ស្រង់បូកពិន្ទុ និងប្រកាសលទ្ធផល

-ចំពោះការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងបានកែសម្រួលយន្តការ និងនីតិវិធីគ្រប់គ្រង និងតាក់តែងប្រធានវិញ្ញាសា។ វិញ្ញាសាមាន ២ ប្រភេទ គឺថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់ វិទ្យាសាស្ត្រសង្គម និងមានវិញ្ញាសាប្រឡងតែ ៧ មុខវិជ្ជាលើ ១០ មុខវិជ្ជាដែល សិស្សបានរៀន។ ប្រធានវិញ្ញាសាមាន ២ ទម្រង់ គឺទម្រង់អូសចែកបេក្ខជន និងកត់លើក្ដារខៀន។ ក្រសួងបាន សហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការត្រួតពិនិត្យការប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ ទាំងដំណើរការសំណេរទាំងដំណើរការកំណែ និងដំណើរការស្រង់បូកពិន្ទុ ដោយកុំព្យូទ័រ ដោយធានាបានគោលការណ៍ ៤ យ៉ាង គឺ ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផល ទទួលយកបាន។ ក្រសួងបានកែសម្រួលសមាសភាព និយាមគណៈមេប្រយោគ និងបានបង្កើនកម្រៃប្រចាំថ្ងៃរបស់គណៈមេប្រយោគគ្រប់កម្រិត ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

-ក្រសួងបានរឹតបន្តឹងដំណើរការប្រឡងជ្រើសរើសក្របខណ្ឌគ្រូបង្រៀនគ្រប់កម្រិត ការប្រឡងបញ្ចប់ និងការប្រឡងប្ដូរប្រភេទក្របខណ្ឌផ្ទៃក្នុង។

វិធានការទី ៤ ៖ ការកែទម្រង់ឧត្តមសិក្សា

-រាជរដ្ឋាភិបាលបានប្រគល់សិទ្ធិជូនគ្រឹះស្ថានឧត្តមសិក្សា ចុះហត្ថលេខាលើសញ្ញាបត្រគ្រប់ប្រភេទ ការចុះហត្ថលេខាលើការបញ្ជាក់វិញ្ញាបនបត្របណ្ដោះអាសន្ន និងសន្លឹកសញ្ញាបត្រ ថតចម្លង និងចេញសន្លឹកសញ្ញាបត្រលើកទី ២

-ក្រសួងបានផ្អាកការអនុញ្ញាតឲ្យបើកគ្រឹះស្ថានឧត្តមសិក្សាឯកជនណា ដែលមិនឆ្លើយតបទៅនឹងវិស័យអាទិភាពក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងទីផ្សារពលកម្ម

-ក្រសួងបានកសាងគោលនយោបាយស្ដីពី ចក្ខុវិស័យឧត្តមសិក្សា ២០៣០ និងកំពុងរៀបចំគោលនយោបាយ ស្ដីពីអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា នៅឧត្តមសិក្សា

-ក្រសួងបានជំរុញឲ្យគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងគ្រឹះស្ថានឧត្តមសិក្សាឯកជន កសាងផែនការយុទ្ធសាស្ត្រ និងបង្កើនសកម្មភាពស្រាវជ្រាវរបស់សាស្ត្រាចារ្យ និងនិស្សិត

-ក្រសួងបានបង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការកម្ពុជា។

វិធានការទី ៥ ៖ ការអភិវឌ្ឍសម្រាប់យុវជន នូវជំនាញបច្ចេកទេស និងជំនាញទន់

-រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជន។ ក្រសួងកំពុងរៀបចំផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជន

-បង្កើតលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍយុវជន ។ សហការជាមួយក្រុមហ៊ុនសែលខាត ដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា នៅតាមមជ្ឈមណ្ឌលយុវជន និងគ្រឹះស្ថានសិក្សាមួយចំនួន

-រាជរដ្ឋាភិបាលបានសម្រេចរក្សាទុកទីតាំងមជ្ឈមណ្ឌលយុវជនខេត្តសៀមរាប ឱ្យនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្ដល់ឱកាសដល់យុវជនទទួលបានការអភិវឌ្ឍ ជំនាញបច្ចេកទេស និងជំនាញទន់

-ក្រសួងបានរៀបចំម៉ូឌុលនិងបានបណ្ដុះបណ្ដាលជំនាញខ្លីៗ ស្ដីពីសហគ្រិនភាព និងស្មារតីស្ម័គ្រចិត្ត ដល់យុវជននៅតាមមជ្ឈមណ្ឌលយុវជន និងដាក់ឱ្យអនុវត្តនូវមជ្ឈមណ្ឌលបច្ចេកវិទ្យា ក្នុង គោលដៅបណ្ដុះបណ្ដាលយុវជននូវជំនាញព័ត៌មានវិទ្យា។

វិធានការទី ៦ ៖ ការអនុវត្តស៊ីជម្រៅកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-ក្រសួងបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តិស្ដីពីគោលការណ៍ចំណាយនានា ដូចជា ប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ស្ដីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា ដោយបានបង្កើនថវិកាសម្រាប់មុខចំណាយនីមួយៗ អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៤ ស្ដីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាព អន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ ដោយបានបង្កើនប្រាក់អាហា

រូបករណ៍ និងរបបឧបត្ថម្ភ ជីវភាពអន្តេវាសិកដ្ឋានសម្រាប់ សិស្ស និស្សិត។

-ក្រសួងបានណែនាំ និងផ្ទេរសិទ្ធិដល់អង្គភាពជំនាញ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្នុងការគ្រោងចំណាយសម្រាប់ពីឆ្នាំ២០១៥តទៅ រួមបញ្ចូលទាំងការអនុវត្តថវិកាកម្មវិធីពេញលេញ

-ក្រសួងបានចាត់តាំងក្រុមការងារលទ្ធកម្ម ទទួលខុសត្រូវលើការធ្វើលទ្ធកម្មគ្រប់ប្រភេទ សំដៅបង្កើនប្រសិទ្ធភាព និងតម្លាភាព។ ជាក់ស្តែងក្រសួងបានសន្សំថវិកាប្រមាណ ៧លានដុល្លារ ដែល ត្រូវបានយកទៅបង្កើនប្រាក់បៀវត្សមន្ត្រីអប់រំ

-ក្រសួងបានពិនិត្យឡើងវិញលើការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងយានយន្តគ្រប់ ប្រភេទ ។ក្រសួងបានជំរុញ និងពង្រឹងការគ្រប់គ្រងបញ្ជីអចលនទ្រព្យ ដោយរៀបចំឲ្យមានប័ណ្ណកម្មសិទ្ធិទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-ក្រសួងបានរៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពីការងារសវនកម្មថវិកាកម្មវិធី និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់យោបល់។

វិធានការទី ៧ ៖ ការកែទម្រង់ការងារអប់រំកាយ និងកីឡា

-ក្រសួងបញ្ចប់ការរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា

-ក្រសួងគ្រោងបង្កើតគណៈកម្មការគ្រប់គ្រងការអភិវឌ្ឍពហុកីឡដ្ឋានជាតិអូឡាំពិក តាមរយៈភ្នាក់ងារប្រតិបត្តិការពិសេស សំដៅកែលម្អទីលានកីឡា សាលដំបូលទូក ប្រព័ន្ធបង្ហូរទឹក និង អគាររដ្ឋបាល

-ក្រសួងបានសហការជាមួយសហព័ន្ធកីឡាបាល់ទាត់កម្ពុជា ប្រមូលផ្តុំកីឡាករអាយុ ក្រោម ១៤ ឆ្នាំ ដើម្បីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌល និងសាលាបាត់ទាត់ជាតិទន្លេបាទី សម្រាប់ការត្រៀមលក្ខណៈចូលរួមការប្រកួតស៊ីហ្គេមនៅឆ្នាំ២០២៣ ដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះ

-បង្កើតផែនការបណ្តុះបណ្តាលជាថ្នាលត្រៀមកីឡាករជំនាន់ថ្មី សម្រាប់ការត្រៀមលក្ខណៈចូលរួម ការប្រកួតស៊ីហ្គេមនៅឆ្នាំ២០២៣។ ការបណ្តុះបណ្តាលគ្រូបង្វឹក អាជ្ញាកណ្តាល និងភ្នាក់ងារ ប្រឆាំងដូប្បា

-ក្រសួងបានអនុវត្តអនុក្រឹត្យ លេខ ៥៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភី និងប្រាក់ឧបត្ថម្ភគ្រូបង្វឹកក្នុងការប្រកួតកីឡា លក្ខណៈអន្តរជាតិ គឺមេដាយមាស ៤០ លានរៀល មេដាយប្រាក់ ៣០ លានរៀល និងមេដាយសំរិទ្ធ ១៦ លាន រៀល។

វិធានការទី ៨ ៖ ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ

-ក្រសួងបានបង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំដើម្បីជួយដល់ការសិក្សាស្រាវជ្រាវ និងកែលម្អគោលនយោបាយអប់រំ។

២. បញ្ហាប្រឈម

-គុណភាពកម្រិតខ្ពស់របស់គ្រូបង្រៀនដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច

-ការបង្កើនបរិមាណ និងសមត្ថភាពក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា

-ការពិនិត្យឡើងវិញ និងកែលម្អការប្រមូលទិន្នន័យស្តីពីតម្រូវការសៀវភៅសិក្សា សម្ភារបរិក្ខារនានា កែលម្អប្រព័ន្ធបែងចែក និងការគ្រប់គ្រង

-ការលំបាកក្នុងការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ដោយទីតាំងធនាគារមានចំនួនតិចហើយស្ថិតនៅឆ្ងាយពីអង្គភាពបម្រើការងារ

-ការរៀបចំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូចេញថ្មីមួយចំនួន

-ការគ្រប់គ្រងមន្ត្រីរាជការ គ្រូបង្រៀនពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យានៅតាមអង្គភាពមួយចំនួន

-ការផ្តល់ថវិកាកម្មវិធីសម្រាប់ដំណើរការសាលារៀនមិនទាន់បានបើកគណនីតាមប្រព័ន្ធធនាគារ

-ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាមិនទាន់ដំណើរការ

-គ្រឹះស្ថានឧត្តមសិក្សាមានសកម្មភាពស្រាវជ្រាវតិចតួច

-ទីលានហ្វឹកហ្វឺនកីឡាករ និងទីលានប្រកួតពុំទាន់មានភាពល្អប្រសើរ ឆ្លើយតបទៅនឹងលក្ខណៈបច្ចេកទេស

-ពុំទាន់មានមជ្ឈមណ្ឌលកីឡាភូមិភាគ ដើម្បីគាំទ្រសកម្មភាពប្រមូលផ្តុំថ្នាក់ជាតិឲ្យកាន់តែមាន

ប្រសិទ្ធភាព ។

៣.វិធានការដោះស្រាយ

វិធានការទី ១ ៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ

-បង្កើនការលើកទឹកចិត្តដល់សិស្សពូកែនិងគ្រូបង្រៀនមានស្នាដៃ ។ ការលើកទឹកចិត្តនឹងត្រូវផ្តោតលើការលើកទឹកចិត្តផ្នែកសង្គមជាជាង ផ្នែកហិរញ្ញវត្ថុ ធានាយ៉ាងណាឱ្យសិស្សពូកែថ្នាក់ជាតិ លើមុខវិជ្ជាណាមួយត្រូវបានគេទទួលស្គាល់និងកោតសរសើរជាទូទៅ។ ការលើកទឹកចិត្តស្រដៀងគ្នានេះ ក៏នឹងត្រូវរៀបចំសម្រាប់គ្រូបង្រៀនមានស្នាដៃផងដែរ

-ពង្រឹងការងារអធិការកិច្ច តាមរយៈការបណ្តុះបណ្តាលអធិការប្រមាណ ៤០០ នាក់ដើម្បីពិនិត្យមើលការបង្រៀន និងរៀនជាពិសេសនៅថ្នាក់ទី ៩ និងទី ១២ ការរៀបចំផែនការសកម្មភាព អធិការកិច្ច និងដំណើរការអធិការកិច្ចនៅតាមសាលារៀន

-លើកកម្ពស់គុណភាព និងប្រសិទ្ធភាពរបស់គ្រូបង្រៀនតាមរយៈការបណ្តុះបណ្តាល

-ពង្រឹងការគ្រប់គ្រងនៅតាមសាលារៀន តាមរយៈការបង្កើតឲ្យមានក្រុមប្រឹក្សាភិបាលសាលារៀន និងការលើកកម្ពស់សមត្ថភាពរបស់នាយកសាលា

-យកចិត្តទុកដាក់លើការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា និងបច្ចេកវិទ្យា ជាពិសេសការរៀបចំឲ្យមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងបណ្ណាល័យនៅតាមសាលារៀន

-លើកកម្ពស់ការអប់រំពេញមួយជីវិត ការអប់រំអំពីភាពជាពលរដ្ឋសកល ការអប់រំពីចម្ងាយ និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជំរុញការបង្កើតឲ្យមានមូលនិធិសមធម៌ និងសាលារៀនជំនាន់ថ្មីសម្រាប់អនាគត

-លើកកម្ពស់គុណភាពអប់រំនៅគ្រប់កម្រិត ជាពិសេសការបង្កើតសាលាគំរូតាមរូបភាពបត់បែន និង ផ្តួចផ្តើមដោយរាជរដ្ឋាភិបាល ព្រមទាំងការពិនិត្យលើការផ្តល់សេវាអប់រំពីសំណាក់ផ្នែកឯកជន

-បង្កើនបរិមាណ និងគុណភាពក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ដើម្បីអនុវត្តគោលនយោបាយជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូចឲ្យកាន់តែមានប្រសិទ្ធភាព

-ពង្រឹងការងារគ្រប់គ្រងរបស់នាយកសាលា ការបង្រៀនរបស់គ្រូ និងតួនាទីភារកិច្ចរបស់គណៈកម្មការ ទ្រទ្រង់សាលា

-បញ្ចប់ការរៀបចំផែនការសកម្មភាពស្តីពីការអភិវឌ្ឍគ្រូបង្រៀន ដោយរួមបញ្ចូលការដំឡើងប្រាក់បំណាច់ ផែនការពង្រាយគ្រូ ការបង្កើនគុណវុឌ្ឍិ ការដាក់ឲ្យអនុវត្តឧបករណ៍វាយតម្លៃគ្រូបង្រៀន ការជ្រើសរើសគ្រូតាមរយៈឯកទេសកម្មគ្រូបង្រៀន

-រៀបចំផែនការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាពិសេសនាយកសាលារៀន

-បង្កើតគណៈកម្មការពិនិត្យការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា និងវិទ្យាសាស្ត្រ

-ជំរុញការបង្កើតក្លឹបសិក្សានៅតាមគ្រឹះស្ថានសិក្សា និងការបង្រៀនមុខវិជ្ជា គណិតវិទ្យា និងភាសាខ្មែរ

-រៀបចំផែនការសាងសង់អន្តេវាសិកដ្ឋានសម្រាប់គ្រូបង្រៀននៅតំបន់ជួបការលំបាក ។

វិធានការទី ២ ៖ ការពង្រឹងការគ្រប់គ្រងបុគ្គលិក

-យកចិត្តទុកដាក់សិក្សាអំពីការបង្កើនប្រាក់បង្រៀនបន្ថែមម៉ោងនៅតំបន់ជនបទ។ សិក្សាអំពីការបង្កើនប្រាក់បំណាច់គ្រូបង្រៀននៅតំបន់ជនបទ

-រៀបចំផែនការសកម្មភាពសម្រាប់ពង្រឹងការងារគ្រប់គ្រងបុគ្គលិក

-កែសម្រួល និងដាក់ឲ្យអនុវត្តនិយាមប្រើប្រាស់បុគ្គលិក

-ដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃការងារបុគ្គលិក ផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធលើកទឹកចិត្ត

-ពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផ្តល់ប្រាក់ឧបត្ថម្ភគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកឲ្យបានសមស្រប

-ពិភាក្សា និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈ ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ

សម្រាប់តែងតាំងមន្ត្រីនៅថ្នាក់ក្រោមជាតិឲ្យមានការឯកភាពគ្នា

-រៀបចំនីតិវិធីក្នុងការជ្រើសរើសគ្រូតាមមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូ។

វិធានការទី ៣ ៖ ការពង្រឹងការប្រឡងគ្រប់ប្រភេទ

-បន្តពង្រឹងគុណភាពប្រឡងដោយអនុវត្តគោលការណ៍ ៤ យ៉ាង គឺគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន

-បន្តលុបបំបាត់ភាពអនាធិបតេយ្យ និងការសូកប៉ាន់ក្នុងការប្រឡងគ្រប់ប្រភេទ ដើម្បីលើកស្ទួយការគោរពគ្រូបង្រៀន និងស្តារឡើងវិញនូវកិត្តិយសរបស់គ្រូបង្រៀន

-ពិនិត្យលទ្ធភាពការរៀបចំវិញ្ញាសាមុខវិជ្ជាចម្រុះ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

វិធានការទី ៤ ៖ ការកែទម្រង់ឧត្តមសិក្សា

-សិក្សាលទ្ធភាពរបស់សាកលវិទ្យាល័យមួយ ដើម្បីអនុវត្តកម្មវិធីពិសេស ដែលផ្តួចផ្តើមគាំទ្រដោយថវិការាជរដ្ឋាភិបាល ជាពិសេសផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិស្វកម្ម

-ពង្រីកលទ្ធភាពចូលរៀននៅឧត្តមសិក្សារបស់និស្សិតជួបការលំបាក តាមរយៈការបង្កើនចំនួនអាហារូបករណ៍ដល់សិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

-បង្កើនសកម្មភាពស្រាវជ្រាវរបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា

-លើកទឹកចិត្តក្នុងការបណ្តុះបណ្តាលលើមុខជំនាញអាទិភាព សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម មានមុខវិជ្ជាដូចជា វិទ្យាសាស្ត្រ គណិតវិទ្យា បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍។ល។ តាមរយៈការជំរុញបង្កើតមហាវិទ្យាល័យវិស្វកម្ម និងការបណ្តុះបណ្តាល អ្នកជំនាញកម្រិតមធ្យម

-ជំរុញការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាសាកលវិទ្យាធិការកម្ពុជា

-បញ្ចប់ការរៀបចំក្របខណ្ឌការងារថ្មីសម្រាប់ការងារទទួលស្គាល់គុណភាពអប់រំ និងបញ្ចប់ការរៀបចំឧបករណ៍វាយតម្លៃថ្មីសម្រាប់ទទួលស្គាល់គុណភាពអប់រំ

-រៀបចំយន្តការ និងបញ្ចូលសាស្ត្រាចារ្យបរទេសទៅក្នុងក្រុមការងារវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា

-ពិនិត្យឡើងវិញសមាសភាពរបស់គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា

-ជំរុញការរៀបចំផែនការបណ្តុះបណ្តាលសាស្ត្រាចារ្យ ការបង្កើតបណ្ណាល័យ និងលើកទឹកចិត្តការស្រាវជ្រាវ។

វិធានការទី ៥ ៖ ការអភិវឌ្ឍសម្រាប់យុវជន នូវជំនាញបច្ចេកទេស និងជំនាញទន់

-រៀបចំផែនការសកម្មភាពជាតិ ដើម្បីអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយុវជន

-ជំរុញសកម្មភាពក្រុមប្រឹក្សាកុមារ និងយុវជន នៅតាមសាលារៀនឲ្យចូលរួមក្នុងការងារសហគមន៍ និងសង្គម

-ផ្តល់ការបណ្តុះបណ្តាលជំនាញទន់ដល់យុវជនបាត់បង់ឱកាស តាមរយៈកម្មវិធីបណ្តុះបណ្តាលនៅតាមមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត

-បង្កើតអគ្គលេខាធិការដ្ឋានដើម្បីសម្របសម្រួលការងារយុវជន

-រៀបចំគោលនយោបាយដើម្បីដំណើរការក្រុមប្រឹក្សាការងារ

-សហការជាមួយក្រុមហ៊ុន Mobitel ដើម្បីដំណើរការមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យា ព័ត៌មានវិទ្យា

-ជំរុញដំណើរការរបស់មជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត ។

វិធានការទី ៦ ៖ ការអនុវត្តស៊ីជម្រៅកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-ផ្សារភ្ជាប់ទំនាក់ទំនងរវាងការរៀបចំថវិកាទៅនឹងគោលនយោបាយអប់រំ

-ជំរុញដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងវិស័យអប់រំ

-បើកគណនីតាមប្រព័ន្ធធនាគារសម្រាប់អនុវត្តថវិកាដំណើរការសាលារៀន ដោយពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បន្តជំរុញឲ្យមានគោលការណ៍ ឬការណែនាំស្តីពីការពន្លឿនការបើកផ្តល់បុរេប្រទានថវិកាសម្រាប់ដំណើរការសាលារៀន

-បង្កើនបរិមាណ និងធានាគុណនេយ្យភាពថវិកាដំណើរការសាលារៀន ដើម្បីធានាការអនុវត្តផែនការអភិវឌ្ឍសាលារៀន ការកាត់បន្ថយជម្លោះនៅក្នុងសាលារៀន ការផ្តល់ថវិកាសាលារៀន តាមរយៈប្រព័ន្ធធនាគារ និងការបើកថវិកាឱ្យទាន់ពេលវេលា

-ធានាការរក្សាទុក និងការកាប់អគារ និងទ្រព្យសម្បត្តិដែលជារបស់រដ្ឋ

-ជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។

វិធានការទី ៧ ៖ ការកែទម្រង់ការងារអប់រំកាយ និងកីឡា

-បញ្ចប់ការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា

-ជំរុញសកម្មភាពអប់រំកាយ និងកីឡានៅតាមសាលារៀនគ្រប់កម្រិត

-លើកកម្ពស់សិទ្ធផលរបស់កីឡាករជម្រើសជាតិដើម្បីចូលរួមការប្រកួតកីឡានៅក្នុងតំបន់ និងអន្តរជាតិ

-បន្តជួសជុលកែលម្អពហុកីឡដ្ឋានជាតិអូឡាំពិក មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា និងទីលានប្រកួតឲ្យបានសមស្របតាមស្តង់ដាបច្ចេកទេស

-រៀបចំផែនការបណ្តុះបណ្តាលកីឡាករសម្រាប់ត្រៀមការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣

-ជំរុញការប្រកួតកីឡានៅតាមសាលារៀន

-រៀបចំផែនការបណ្តុះបណ្តាលគ្រូបង្វឹក ជាពិសេសជំនាញភាសាអង់គ្លេស ដោយសហការជាមួយគណៈកម្មការជាតិអូឡាំពិក និងសហព័ន្ធកីឡា។

វិធានការទី ៨ ៖ ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ

-ដំណើរការក្រុមប្រឹក្សាស្រាវជ្រាវអប់រំដើម្បីលើកកម្ពស់ការកសាងគោលនយោបាយ និងការរៀបចំផែនការអប់រំ

-កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ដោយពង្រឹងផ្នែកគោលនយោបាយ និងការពិនិត្យតាមដាន សួចនាករអប់រំ អគ្គនាយកដ្ឋានអប់រំ និងអគ្គាធិការដ្ឋាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេចតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន